# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ៦ ខែ សីហា ឆ្នាំ២០២០

## អូស្ត្រាលីបើកការគាំទ្រផែនការយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ នៅក្រុងព្រះសីហនុ

ម្សិលមិញ ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ឯកឧត្តម Pablo Kang និងអភិបាលខេត្តព្រះសីហនុ ឯកឧត្តម គួច ចំរើន បានបើកការគាំទ្ររបស់អូស្ត្រាលី លើ "ផែនការយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ" សម្រាប់ក្រុងព្រះសីហនុ។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា "ការរំខានរបស់ជំងឺកូវីដ-១៩ ទាមទារនូវវិធីសាស្ត្រថ្មី និងប្រកបដោយភាពច្នៃប្រឌិត ក្នុងការផ្តល់សេវាកម្ម និងការអភិវឌ្ឍទីក្រុង ព្រោះថវិការបស់រដ្ឋាភិបាល កំពុងរងសម្ពាធ។"

ឧបត្ថម្ភថវិកាដោយ កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) របស់អូស្ត្រាលី នៅកម្ពុជា ផែនការយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ ក្រុងព្រះសីហនុ នឹងរៀបចំក្របខ័ណ្ឌមួយ ពីវិធីដែលធនធានសាធារណៈ អាចជំរុញដល់ការវិនិយោគឯកជន។

យុទ្ធសាស្ត្រនេះ ក៏នឹងស្វែងរកពីវិធីដែលសេវាកម្មសំខាន់ៗរបស់រដ្ឋាភិបាល ដូចជា ការកត់ត្រាតាមដានការប្រើប្រាស់ទឹកភ្លើង ការកំណត់កន្លែងចតរថយន្ត និងការគ្រប់គ្រងចរាចរណ៍ អាចត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង តាមរយៈការប្រើប្រាស់កម្មវិធីឆ្លាតវៃ។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា "កម្មវិធីហេដ្ឋារចនាសម្ព័ន្ធឈានមុខគេរបស់អូស្ត្រាលី នៅកម្ពុជា គឺកម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) - ប្តេជ្ញាជួយក្រុងព្រះសីហនុឱ្យសម្រេចបាននូវចក្ខុវិស័យទីក្រុងឆ្លាតវៃរបស់ខ្លួន។"

"ផែនការយុទ្ធសាស្ត្រទីក្រុងឆ្លាតវៃ នឹងផ្តល់គោលការណ៍ណែនាំដល់រដ្ឋបាលខេត្តព្រះសីហនុ ដើម្បីប្រើប្រាស់កម្មវិធីឆ្លាតវៃប្រកបដោយប្រសិទ្ធិភាព ក្នុងការផ្តល់សេវាកម្មសាធារណៈ ដើម្បីកាត់បន្ថយផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការស្តារសេដ្ឋកិច្ចឡើងវិញ។"

ក្រុងព្រះសីហនុបានឆ្លងកាត់ការអភិវឌ្ឍយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលនាំឱ្យមានគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្មីៗជាច្រើននៅក្នុងទីក្រុង។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍បន្ថែមថា "ដោយសារការផ្លាស់ប្តូរមុខមាត់ និងថែមមានជំងឺកូវីដ-១៩ទៀតនោះ យើងក៏កំពុងធ្វើការយ៉ាងជិតស្និទ្ធ ជាមួយរដ្ឋបាលខេត្តព្រះសីហនុ ដើម្បីធានាថាសេវាសាធារណៈដែលមានគុណភាពខ្ពស់ នៅបន្តផ្តល់ផលប្រយោជន៍ដល់ប្រជាជនខេត្តព្រះសីហនុ។"

ឯកឧត្តម អភិបាលខេត្ត គួច ចំរើន បានមានប្រសាសន៍ថា "រដ្ឋបាលខេត្តព្រះសីហនុ អរគុណដល់ការគាំទ្ររបស់អូស្រ្តាលី និងរំពឹងចាំមើលសេចក្តីព្រាងផែនការយុទ្ធសាស្រ្តក្រុងឆ្លាតវៃ នៅចុងឆ្នាំ ២០២០នេះ។"

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au



រូបថត៖ រដ្ឋបាលខេត្តព្រះសីហនុ



រូបថត៖ រដ្ឋបាលខេត្តព្រះសីហនុ